ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរទន្លេសាប

លេខ :..២៣៧......អទស

# ប្រកាស
# ស្តីពី
# ការធ្វើប្រតិភូកម្មមុខងារអភិរក្សតំបន់ទន្លេសាប

## រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
## និងជាប្រធានអាជ្ញាធរទន្លេសាប

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប
- យោងតាមការចាំបាច់របស់អាជ្ញាធរទន្លេសាប

## សម្រេច

**ប្រការ ១ ៖**

ត្រូវបានធ្វើប្រតិភូកម្មមុខងារអភិរក្សតំបន់ទន្លេសាប ជូនមន្ទីរធនធានទឹក និងឧតុនិយមខេត្តទាំង៨ (ប្រាំបី)ជុំវិញបឹងទន្លេសាប រួមមាន ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល និងខេត្តកំពង់ចាម ។



អគារលេខ ៥៧៦, ផ្លូវជាតិលេខ ២, សង្កាត់ ចាក់អង្រែក្រោម, ខណ្ឌ មានជ័យ, រាជធានីភ្នំពេញ, ទូរស័ព្ទ / ទូរសារលេខ: (៨៥៥) ២៣ ៧២៧ ៤៥៤
#576, National Road No 2, Sangkat Chak Angre Krom, Khan Meanchey, Phnom Penh, Cambodia, Phone / Fax : (855) 23 727 454 Website: www.tonlesap.gov.kh

**ប្រការ ២ ៖**

មន្ទីរធនធានទឹក និងឧតុនិយមខេត្តទាំង៨(ប្រាំបី) ត្រូវអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មអភិរក្សតំបន់ទន្លេសាបដូចខាងក្រោម៖

- ជាជនបង្គោលអភិរក្សតំបន់ទន្លេសាប
- តាមដាន ត្រួតពិនិត្យ និងប្រមូលព័ត៌មានរាល់សកម្មភាពពាក់ព័ន្ធនឹងការធ្វើអាជីវកម្មខុសច្បាប់ និងបទល្មើសនានានៅក្នុងតំបន់ទន្លេសាប
- ចូលរួមការពារថែរក្សា ទប់ស្កាត់ និងការប្រើប្រាស់ធនធានធម្មជាតិ ជីវចម្រុះ និងធនធានទឹកក្នុងតំបន់ទន្លេសាប
- សម្របសម្រួល និងទទួលពាក្យបណ្តឹងរាល់វិវាទនានា ដែលកើតឡើងនៅក្នុងតំបន់បឹងទន្លេសាប
- សហការជាមួយអាជ្ញាធរដែនដី និងមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្ត ដើម្បីគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប
- រៀបចំផែនការសកម្មភាពចូលរួមការពារថែរក្សា ទប់ស្កាត់ និងការប្រើប្រាស់ធនធានធម្មជាតិ ជីវចម្រុះ និងធនធានទឹកក្នុងតំបន់ទន្លេសាប
- ផ្តល់ព័ត៌មាន និងរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប
- បំពេញភារកិច្ចផ្សេងទៀតដែលប្រធានអាជ្ញាធរទន្លេសាបប្រគល់ជូន ។

ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តទាំង៨(ប្រាំបី) ជាប្រធានជនបង្គោលអភិរក្សតំបន់ទន្លេសាប ។

**ប្រការ ៣ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ ៖**

អនុប្រធានអាជ្ញាធរទន្លេសាប អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គនាយកនៃអគ្គនាយកកិច្ចការបច្ចេកទេស អគ្គាធិការនៃក្រសួងធនធានទឹក និងឧតុនិយម ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តទាំង៨ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសុក្រ ៥ រោច ខែផល្គុន ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**និងជា ប្រធានអាជ្ញាធរទន្លេសាប**

**ថោ_ជេដ្ឋា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ